**មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)


# កំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៊ម តំបន់ទី ៧

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃច័ន្ទ ទី១១ ខែធ្នូ ឆ្នាំ២០០៦**

**ក្រុងកែប**

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**


*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយ លោក **ឡារី ស្រ្តេនន្ទ (Larry Strange)** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៊ម (COPCELPROM) ដោយ លោក **ឱក សេរី សោភក្តិ** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

៣. ស្ថានភាពទូទៅ នៃការរៀបចំការបោះឆ្នោត ថ្លែងដោយ លោក **ម៉ុក សែន** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតក្រុងកែប

៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងក្រុងកែប

៥. សេចក្តីផ្សេងៗ

### ១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក ឡារី ស្រ្តេនន្ទ (Larry Strange) នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

លោក **លោក ឡារី ស្រ្តេនន្ទ** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

បានថ្លែងអំណរគុណដល់ឯកឧត្តម ហាស់ សារ៉េត អភិបាលក្រុងកែប និងលោក ម៉ុក សែន ដែលជាប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតក្រុងកែប ដែលបានអនុញ្ញាត និងគាំទ្រចំពោះយន្តការ ខប់សែលប្រ៊ម នៅក្នុងក្រុងកែបនេះ ។ ជោគជ័យទាំងឡាយរបស់យន្តការខប់សែល គឺអាស្រ័យដោយមានការចូលរួមយ៉ាងសកម្ម និងផុលផុសពីសំណាក់ អស់លោក លោកស្រី ដែលបានចូលរួមនៅក្នុងពេលនេះ ។

វិទ្យាស្ថាន CDRI មានកិត្តិយស និងសេចក្តីរីករាយណាស់ដែលនៅក្នុងការអនុវត្តន៍កម្មវិធីទាំងឡាយទទួលបានការគាំទ្រយ៉ាងពេញទំហឹង និងយ៉ាងសកម្មពីភាគីពាក់ព័ន្ធនានា ជាពិសេសរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ អាជ្ញាធរខេត្ត គជប និងគណកម្មាការរៀបចំការបោះឆ្នោតខេត្តក្រុង អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធនានាមួយចំនួន ។

លោក បានបង្ហាញដោយត្រួសៗថា ហេតុអ្វីបានជាវិទ្យាស្ថាន CDRI រៀបចំកម្មវិធីខប់ដែលនេះឡើង ។ វិទ្យាស្ថាន CDRI គឺជាស្ថាប័នមួយធ្វើការ ស្រាវជ្រាវដោយឯករាជ្យ ដែលបានស្រាវជ្រាវទៅលើគោលនយោបាយផ្សេងៗ ហើយមិនពាក់ព័ន្ធទៅ និងនយោបាយ ឬគណបក្សនយាបាយណាមួយឡើយ វិទ្យាស្ថាន CDRI បានធ្វើការស្រាវជ្រាវទៅលើវិស័យ៥ ដែលជាវិស័យសំខាន់ៗនៅក្នុងការជំរុញឱ្យមានការអភិវឌ្ឍន៍ប្រកបដោយចិរភាព ដែលមានដូចជា សេដ្ឋកិច្ច និងអភិវឌ្ឍន៍ ពាណិជ្ជកម្ម ការអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៏វិស័យកសិកម្មជនបទ ការអភិវឌ្ឍន៍ជីវភាពរស់នៅ អភិបាលកិច្ចល្អ ប្រកបដោយលទ្ធិប្រជាធិបតេយ្យ កំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន សន្តិសុខមនុស្ស និងការដោះស្រាយទំនាស់ ។ ជាទស្សនៈវិស័យរបស់ វិទ្យាស្ថាន CDRI ដើម្បីឱ្យវិស័យទាំង ៥ ដំណើរការប្រកបដោយភាពរលូន និងល្អ យើងត្រូវការចាំបាច់ណាស់នូវការកសាងលទ្ធិប្រជាធិបតេយ្យមួយឱ្យបានរឹងមាំ និងពិតប្រាកដក្នុងប្រទេសកម្ពុជា ដោយមើលឃើញពីសារៈសំខាន់នេះហើយបានជាវិទ្យាស្ថាន CDRI បានព្យាយាម និងធ្វើការជាមួយភាគីពាក់ព័ន្ធនានា ជាពិសេសរឿងការងារបោះឆ្នោត ដើម្បីធ្វើយ៉ាងណាជំរុញឱ្យមានការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌ ដោយគ្មានហិង្សា ព្រមទាំងមានវប្បធម៌នៃការជជែកពិភាក្សា ។

លោក បានជំរុញឱ្យមានការលើកឡើងនៅបញ្ហាអ្វីៗ ដែលពាក់ព័ន្ធទៅនិងក្តីកង្វល់របស់អ្នកចូលរួមដែលមាន នៅក្នុងក្រុងកែបនេះ ដោយជំរុញឱ្យមានការលើកយកមកពិក្សាគ្នាត្រង់ទៅត្រង់មក ដោយបើកទូលាយតែម្តង ។ ហើយ លោក ក៏សូមជូនពរឱ្យការពិភាក្សាគ្នានេះប្រកបដោយផ្លែផ្កា និងទទួលបានលទ្ធផលជាវិជ្ជមាន ។

## ២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក ឱក សេរី សោភក្តិ៍ ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

លោក **ឱក សេរី សោភក្តិ៍** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះលោក Larry Strange ដែលបានមានប្រសាសន៍ប្រកបដោយអត្ថន័យដ៏ទូលំទូលាយចំពោះវិទ្យាស្ថាន CDRI ក្នុងការរៀបចំយន្តការខប់សែល ជាពិសេសខប់សែលប្រ៉ម ។ ខប់សែលពាក្យពេញគឺយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ។ ដោយលោកបានធ្វើការតស៊ូនៅជាយដែនចំនួន ១១ ឆ្នាំ ឃើញការលំបាកវេទនា ការស្លាប់ ការដែលប្រជាពលរដ្ឋត្រូវគេធ្វើបាប ហើយវិនាសហិនហោចដោយសារសង្គ្រាម អស់រយៈពេល២៨ ឆ្នាំ ទម្រាំតែយើងក៏សាងបាន មានទឹកភ្លើង មានផ្លូវ បើយើងគិតត្រឡប់ថយក្រោយវិញ គឺការក៏សាងនេះបានមកដោយលំបាកណាស់ ហើយបើសិនជាមានសង្គ្រាមឡើងវិញម្តងទៀត ការរលាយរហ័សណាស់ មិនចាំបាច់ប្រើពេលច្រើនទេ តែមួយភ្លែតបាត់ទៅវិញអស់ ហើយនិងក្លាយទៅជាយុគសម័យខ្មៅងងឹតឡើងវិញទៀត ។ ដូច្នេះគោលបំណងធំរបស់យើងជំនាន់នេះ និងជាមរតក សម្រាប់ខ្មែរជំនាន់ក្រោយ ធ្វើយ៉ាងណាកុំឱ្យត្រឡប់ទៅអតីតកាលដ៏សោកសៅនោះទៀត ។ លោកចេះតែគិតថា តើធ្វើយ៉ាងណា? នៅពេលដែលបានធ្វើជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង ពីឆ្នាំ ១៩៩៣ រហូតដល់ឆ្នាំ ១៩៩៨ ដែលបានរៀបចំជាមួយគាត់តាំងពីឆ្នាំ ១៩៩៤មក គឺរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ យើងគ្រោងបោះនៅឆ្នាំ ២០០០ ប៉ុន្តែ ដល់យឺតយើងជំរុញដល់ឆ្នាំ ២០០២ ទើបបានបោះ ។ ហើយនៅពេលដែលបានបោះរហូតទៅដល់យើងមើលឃើញហើយឆ្នាំ ១៩៩៨, ២០០២ , ២០០៣, ២០០៦ អ៊ុនតាក់រៀបចំឱ្យយើងពី ឆ្នាំ ១៩៩៣ វិទ្យាស្ថាន CDRI បានធ្វើការសិក្សាស្រាវជ្រាវមួយថា ហេតុអ្វីបាន ជានៅឆ្នាំ ១៩៩៨ ការបោះឆ្នោតមានទំនាស់ មានរហូតដល់ការកាប់សម្លាប់ មានរូបភាពមិនល្អនៅទូរទស្សន៍ CNN របស់អាមេរិច ពេញទាំងសកលលោក ធ្វើឱ្យមានរូបភាពកេរ្តិ៍ឈ្មោះរបស់ព្រះរាជាណាចក្រកម្ពុជាអាប់ឱននៅក្នុងឆាកអន្តរជាតិ ។

យើងបានរកឃើញទំនាស់មួយចំនួន ដែលជាទំនាស់ស៊ីជម្រៅ ហើយលោកចេះតែគិតថាធ្វើយ៉ាងម៉េចដើម្បីដោះស្រាយរឿងទាំងអស់នេះបាន ហើយដោះស្រាយទម្លាប់នៅក្នុងសង្គមខ្មែរយើង ដែលនៅមុខគ្នាយើងគួរសមជាមួយនិងគ្នា យើងមិនសូវលើកបញ្ហាយើងច្រើនតែបញ្ចៀសបញ្ហា ប៉ុន្តែនៅក្រោយខ្នងគ្នាគឺយើងនិយាយចាស់ដៃតែម្តង ។ អញ្ចឹងបានជាលោកគិតថាទំនាស់អ្វីៗដែលកើតឡើងគឺ សុទ្ធតែការមិនយល់គ្នា ការដែលបកស្រាយទៅតាមចិត្តរបស់ខ្លួន ការដែលមិនស្តាប់គ្នាទៅវិញទៅមក ការដែលមិនព្រមលើកបញ្ហាទាំងអស់មកដាក់លើតុ ហើយជជែកគ្នាដោយត្រង់ទៅត្រង់មក ។ ក្នុងគំនិតនេះបានជាយើងចាប់ផ្តើមគិតថាគួរតែមានយន្តការមួយ បើសិនជាយើងមូលគ្នាថា យើងលេងល្បែងប្រជាធិបតេយ្យមែន យើងគួរតែមានយន្តការមួយដើម្បីនិងបង្ការទំនាស់ យើងមិនបានបង្ការទំនាស់បាន ១០០% ទេ ហើយយើងក៏មិនបានជជែកគ្នា ហើយយើងយល់គ្នា យល់ព្រមទាំងអស់គ្នាដែរ ប៉ុន្តែបើសិនជាយើងមានឱកាសជជែកគ្នា យល់គ្នាទៅវិញទៅមក យ៉ាងហោចណាស់ក៏យើងបានយល់ថា ហេតុអ្វីបានជាអ្នកដ៏ទៃឯទៀតគេមិនឯកភាពជាមួយយើង ហេតុអ្វីបានជាជំហររបស់គេខុសឆ្ងាយពីយើង ការយល់គ្នានេះហើយដែលធ្វើឱ្យយើងទំនាក់ទំនង ហើយបន្តការកសាងនូវ

វប្បធម៌ជជែកពិភាក្សាគ្នាទុកចិត្តគ្នា ហើយដោះស្រាយបញ្ហាជាមួយគ្នា ព្រោះបើសិនជាមិនជជែកគឺប្រើកម្លាំងហើយ អស់ពីប្រើដៃគឺប្រើអាវុធ តែការប្រើអាវុធ អ្វីដែលយើងខំកសាងមកជាង ១០ ឆ្នាំនិងរលត់រលាយទៅម្តងទៀត ។

អញ្ចឹងហើយបានជាយន្តការខប់សែលនេះបានបង្កើតឡើងនៅថ្នាក់ជាតិ ពីឆ្នាំ ១៩៩៩ រហូតដល់ឆ្នាំ២០០៣ យើងជំនុំគ្នា ៥០ ដងមួយខែម្តងមិនដែលខានទេ ទោះជាភ្លៀងទឹកលិចក៏ដោយ។ ដល់យើងធ្វើបាន៥០ ដងអញ្ចឹងទៅបានយើងចាប់ផ្តើមគិតថាគណបក្សនយោបាយធំៗទាំង៣ អង្គការសង្គមស៊ីវិល គជប គណបក្សនយោបាយទាំងអស់ សហគមន៍អន្តរជាតិ រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង៤ទៀត បានចូលរួមប្រជុំ ដូច្នេះហើយបានជាយន្តការនេះចាប់ផ្តើមឡើង ។ យន្តការនេះគឺធ្វើដោយដៃរបស់ខ្មែរសុទ្ធសាធ មិនបានយកមេរៀនពីណាមកទេ នៅពេលដែលបានគូសវាសយន្តការនេះ ឡើងគឺដោយចិត្តចង់បង្កើតឱ្យមានវប្បធម៌នៃការពិភាក្សាគ្នាកសាងទំនុកចិត្តគ្នា ដោយសារបានឃើញការវិនាសខ្ទេចផ្សារ ហើយ១១ ឆ្នាំ នៅជាយដែន លោកឃើញគេធ្វើបាបប្រជាពលរដ្ឋខ្លាំងណាស់ ពិបាកនិងទ្រាំមើលណាស់ ។ ដល់ធ្វើបានជោគជ័យអញ្ចឹងទៅ លោកគិតថា ចប់ហើយនៅឆ្នាំ ២០០៣ ក៏ប៉ុន្តែដល់ពេលដែលយើងរៀបចំការបោះឆ្នោត ២០០៧-២០០៨ អង្គការសហប្រជាជាតិ ជាពិសេស លោក Douglas Gardner ដែលទើបតែមកថ្មីគាត់បានមើលសេចក្តីរាយការណ៍ហ្នឹង គាត់បានអាននៅញ៉ូវយ៉ក ហើយបានមកភ្នំពេញ គាត់ថាយន្តការនេះល្អណាស់ ហើយក៏បានមកជួបលោក Larry Strange និងរូបលោក សូមឱ្យធ្វើបន្តទៅទៀត ព្រោះយន្តការបែបនេះមិនមានទេ នៅក្នុងសកលលោក ជាពិសេសនៅប្រទេសដែលចេញពីសង្គ្រាមយូរអង្វែង ហើយចេះបង្កើតយន្តការជជែកពិភាក្សាគ្នាដោយខ្លួនឯង ព្រោះថាវាជាមេរៀននៃការរៀនសូត្រ មិនមែនគ្រាន់តែជាមេរៀនសម្រាប់ប្រទេសកម្ពុជាទេ គឺជាមេរៀនសម្រាប់ប្រទេសថ្មីៗ ដែលទើបតែចេញពីសង្គ្រាមដូចយើងដែរ ។ អញ្ចឹងហើយបានជា UNDP សុំឱ្យយើងធ្វើបន្ត ៣ឆ្នាំទៀត ពីឆ្នាំ ២០០៦ ដល់ ២០០៨ ដូច្នេះយើងក៏ចាប់ផ្តើម ដំណាក់កាលទី២ នេះ ។ ក៏ប៉ុន្តែលោកក៏គិតពិចារណាទៀតថា កាលមុនយើងធ្វើតែនៅថ្នាក់ជាតិ ប៉ុន្តែលើកនេះដល់យើងយកទំនាស់ យកមកវិភាគស៊ីជម្រៅឃើញទំនាស់ដែលខ្លាំងក្លាសស្រាក់សស្រាំ គឺកើតនៅថ្នាក់មូលដ្ឋាន ហើយកាលដែលដោះស្រាយមិនរួចនៅថ្នាក់មូលដ្ឋានធ្វើឱ្យរឿងហ្នឹងក្លាយទៅជារឿងនយោបាយ ដូច្នេះហើយបានលោករំកិលយន្តការ នៅថ្នាក់ជាតិមកថ្នាក់ខេត្ត ទើបបានជាមាន ខប់សែលប្រ៉ម នេះ ។ ខប់សែលប្រ៉ម មានគោលបំណងធំៗ៣:

**ទី១.** ធ្វើយ៉ាងណាឱ្យការចុះឈ្មោះបោះឆ្នោតក្លាយទៅជាយន្តការដូចយើងដកដង្ហើម ស្លៀកពាក់ ញ៉ាំបាយអញ្ចឹង ទៅអនាគតលោកបានស្រម័យឃើញថាប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ ឆ្នាំ គឺគាត់ដើរទៅស្មៀនឃុំសង្កាត់ក្រុមប្រឹក្សាឃុំសង្កាត់ ហើយចុះឈ្មោះតែម្តង លែងឱ្យការចុះឈ្មោះនៅជាបញ្ហាទៀតហើយ។ នៅស្រុកគេ តែអាយុ ១៨ ឆ្នាំមានកាតមានអត្តសញ្ញាណប័ណ្ណ ទៅចុះឈ្មោះជារឿងធម្មតា មិនត្រូវឱ្យបញ្ហាហ្នឹងនៅជាបញ្ហាទំនាស់កើតបានទៀតទេ ដូច្នេះយើងត្រូវធ្វើយុទ្ធនាការយ៉ាងណា ដើម្បីឱ្យការចុះឈ្មោះនេះ ក្លាយទៅជាយន្តការមួយប្រចាំថ្ងៃរបស់យើងតែម្តង ទៅអនាគត់ ទោះបីយើងមើលមិនទាន់បានភ្លាម ប៉ុន្តែបើយើងធ្វើការសស្រាក់សស្រាំ ជាមួយគ្នា នឹងអាចទៅជាអញ្ចឹង ហើយជាសំណូមពររបស់ លោក សូមកុំអោយមានការដូរឈ្មោះដើម្បីកុំឱ្យមានបញ្ហាដល់ការចុះឈ្មោះបោះឆ្នោត ។

**ទី២.** ធ្វើយ៉ាងណាឱ្យអត្តសញ្ញាណប័ណ្ណជាតិបានដល់ដៃប្រជាពលរដ្ឋខ្មែរគ្រប់គ្នាទាំងអស់ ចំពោះអ្នកដែលមានអាយុ ១៨ ឆ្នាំឡើងគឺត្រូវតែបានដល់ដៃ កុំឱ្យមានបញ្ហាយកលុយកាក់ កុំឱ្យយកបញ្ហាហ្នឹងទៅជាថ្នូ ទាល់តែអ្នកឯងចូលជាមួយខ្ញុំបានខ្ញុំឱ្យប័ណ្ណឬមួយមានបញ្ហារឿងសញ្ជាតិកើតឡើង គឺថាយើងដោះស្រាយបញ្ហាហ្នឹងជាមួយគ្នា ។ អញ្ចឹងហើយបានជាយើងរំភើបណាស់នៅពេលដែលយើងដាក់បញ្ហានៅលើតុជជែកគ្នាជាប់ៗគ្នា ដោយហេតុនេះហើយបានជា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី លោកអានសេចក្តីរាយការណ៍

ហ្នឹងទៅ យល់ថាយើងត្រូវតែដោះស្រាយបញ្ហាហ្នឹងហើយ អញ្ចឹងហើយបានជាដើមឆ្នាំ២០០៦ លោករៀបចំនៅយុទ្ធនាការឆ្នាំ ២០០៦ នេះ ដើម្បីឱ្យអត្តសញ្ញាណប័ណ្ណជាតិបានដល់ប្រជាពលរដ្ឋខ្មែរដែលមានចំនួន ១លាន៩សែននាក់ ឱ្យបានគ្រប់ៗគ្នាតែម្តង ។ គ្រប់ខេត្តទាំងអស់មកទល់ខែធ្នូនេះឃើញថា បានចំនួនពី ៨៥% ទៅ ៩០% ហើយ នៅសល់តែ១០% ទៅ ១៥% ដែលក្រសួងមហាផ្ទៃនៅធ្វើបន្តៗទៀត ។

**ទី៣.** ចង់ឱ្យយន្តការនៃការបោះឆ្នោតក្លាយទៅជាទម្លាប់ប្រជាធិបតេយ្យមួយរបស់យើង ឥឡូវជាពិសេសរបស់កូនខ្មែរនៅថ្ងៃក្រោយឱ្យលែងមានបញ្ហាអសន្តិសុខ បញ្ហាយប់ឡើងឆ្កែព្រូស ការគំរាមកំហែង ការរើសអើង ហើយរឿងអ្វីទៀតជៀសចេញពីយន្តការនៃការបោះឆ្នោតទៅ ។ នេះបានយើងអាចថែរក្សានូវអ្វីដែលយើងបាន កសាងរួមគ្នាអ្វី ដែល ប្រជាពលរដ្ឋខ្មែរកសាង ផ្លូវទឹក ផ្លូវថ្នល់ បឹងបួរស្រែ ភ្លើង របស់យើងទាំងប៉ុន្មានឱ្យនៅឋិតថេរ ឱ្យលែងរត់ទៅនៅ ស្រុកគេទៀត។ ដូចលោក Larry Strange បានមានប្រសាសន៍អម្បាញ់មិញហើយ គឺយន្តការខបសែលបានបង្កើតឡើងដោយដៃ របស់យើងផ្ទាល់ ដោយមិនមានគំនិតមកពីខាងក្រៅទេ យើងមានមោទនៈភាពណាស់ ក៏ប៉ុន្តែអ្នកពិតប្រាកដដែលធ្វើឱ្យយន្តការ ខបសែល ជោគជ័យមិនមែនខ្ញុំ មិនមែន លោក Larry Strange មិនមែនវិទ្យាស្ថាន CDRI គឺអ្នកដែលចូលរួមហ្នឹងឯង ។ ខបសែល ទៅខេត្តណាក៏ដោយ ឯកឧត្តមអភិបាលខេត្ត គ្រប់ខេត្តទាំងអស់តែងតែផ្តល់នៅសំបុត្រអនុញ្ញាតភ្លាមៗ លោកចុះហត្ថលេខាភ្លាមៗ ព្រោះដឹងថា យន្តការនេះជួយ ឱ្យមានវប្បធម៌នៃការជជែកពិភាក្សាគ្នា ជាពិសេសអស់លោក លោកស្រី ទាំងអស់ដែលបានចូលរួមធ្វើឱ្យយន្តការនេះទទួលបាន ជោគជ័យ ។

## ៣. ស្ថានភាពទូទៅ នៃការរៀបចំការបោះឆ្នោតថ្លែងដោយ លោក ម៉ុក សែន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតក្រុងកែប

បានរៀបរាប់ជូនអង្គសិក្ខាសាលាត្រួសៗ នូវស្ថានភាពទូទៅជុំវិញការបោះឆ្នោតនៅក្រុងកែប ដូចខាងក្រោម:

ក្រុងកែបជាតំបន់រដ្ឋបាល និងទេសចរណ៍ដ៏សំខាន់ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានទីតាំងស្ថិតនៅទិសនិរតី នៃរាជធានីភ្នំពេញ ចំងាយ ១៧៥ Km ។ ក្រុងកែបមានផ្ទៃដីសរុបចំនួន ១៥.២៨៧ Km² ផ្ទៃសមុទ្រចំនួន ២២.១៥៥ Km² ។

រដ្ឋបាលដែនដីត្រូវបានចែកចេញជា ២ខណ្ឌ ៥សង្កាត់ និង ១៦ភូមិ ដែលបច្ចុប្បន្នមានប្រជាជនសរុបចំនួន ៣៤.៦៩២ នាក់ ប្រជាជនអាយុ ១៨ឆ្នាំឡើងមាន ១៩.៥៥៣នាក់ ក្នុងនោះស្រី ៩.៩៥៦នាក់ ។ ទូទាំងក្រុងកែបមានការិយាល័យបោះឆ្នោតចំនួន ៣៧ ការិយាល័យ ។

**១. អំពីការចុះឈ្មោះបោះឆ្នោត:** ជារៀងរាល់ឆ្នាំទោះមានការបោះឆ្នោត ឬគ្មានការបោះឆ្នោត ក្រុងកែបអនុវត្តការចុះឈ្មោះអ្នកបោះឆ្នោតបានល្អជាទូទៅ ។ ដោយហេតុនេះ PEC ទទួលលទ្ធផលដូចជា បញ្ជីបោះឆ្នោតឆ្នាំ១១៩៨ មានឈ្មោះ ១៣.២៤៤នាក់ ឆ្នាំ២០០២ មានឈ្មោះ ១៣.៣៣៨នាក់ ឆ្នាំ២០០៣ មានឈ្មោះ ១៦.៩២៦នាក់ ឆ្នាំ២០០៤ មានឈ្មោះ ១៧.០២២នាក់ ឆ្នាំ២០០៥ មានឈ្មោះ ១៧.២៤២នាក់ ឆ្នាំ២០០៦ មានឈ្មោះ ២១.៤០៧នាក់ ។ ដូច្នេះបណ្តាឆ្នាំដែលគ្មានការបោះឆ្នោត តួលេខចុះឈ្មោះពុំសូវកើន សបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋពុំសូវរួតរះទៅចុះឈ្មោះបោះឆ្នោតនៅឡើយ ។ មួយវិញទៀត លោក បានបញ្ជាក់ថាបណ្តាឆ្នាំដែលមានការបោះឆ្នោត តួលេខកើនឡើងជាបង្គួរព្រោះ ១. ប្រជាពលរដ្ឋភ្ញាក់រលឹកប្រកបដោយមនសិការទទួលខុសត្រូវខ្ពស់ ម្ចាស់ការទៅចុះឈ្មោះបោះឆ្នោតបំពេញកាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋ ដើម្បីជ្រើសរើសមេដឹកនាំ កសាងប្រទេសនិងគោរពសិទ្ធមនុស្ស អនុវត្តលទ្ធិប្រជាធិប្បតេយ្យ ។ ២.គ្រប់គណបក្សនយោបាយប្រឹងប្រែងពង្រីកសមាជិករៀងខ្លួនដើម្បីទទួលបានជ័យជំនះ ។ ៣. អជ្ញាធរមូលដ្ឋានពុះពារ និងខ្នះខ្នែងជូនដំណឹង និងដាស់តឿនដល់ប្រជាពលរដ្ឋដែលគ្រប់អាយុបោះឆ្នោត ឱ្យទៅចុះឈ្មោះដោយគ្មានប្រកាន់និន្នា

ការនយោបាយ ឬគណបក្សនយោបាយឡើយ ។ ៤. ក្នុងរយៈពេលចុះឈ្មោះបោះឆ្នោតម្តងៗគ្មានកើតមានអំពើហឹង្សា អំពីភេរវកម្ម ឬការគំរាមកំហែងកើតឡើងឡើយ ។

**២. អំពីការចែកប័ណ្ណព័ត៌មានៈ** កន្លងមក គជប បានអនុញ្ញាតឱ្យចែកប័ណ្ណព័ត៌មាន ដល់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ២០០៥ ។ ជាលទ្ធផល PEC ទទួលបានប័ណ្ណព័ត៌មានសរុប ១៧.២៤២ សន្លឹក ប័ណ្ណព័ត៌មានចែកជូនសមីខ្លួនផ្ទាល់ ៦១៦១សន្លឹក ប័ណ្ណព័ត៌មានចែកជូនតាមរយៈតំណាង ៥៩៩៥សន្លឹក ប័ណ្ណព័ត៌មានដែលបានចែកសរុប ១២.១៥៦សន្លឹក ស្មើ ៧០.៥០% ប័ណ្ណព័ត៌មាននៅសល់មិនបានចែក ៥.០៨៦ សន្លឹក ក្នុងនោះមានអ្នកស្លាប់ ២០០សន្លឹក អ្នកផ្លាស់ចេញ ៣១៤សន្លឹក អ្នកឈ្មោះស្ទួន ៤០សន្លឹក មូលហេតុផ្សេង ៤.៤២៧ សន្លឹក ។ លទ្ធផលដែលទទួលបានពីការចែកប័ណ្ណព័ត៌មានសង្កេតឃើញថា មានប្រជាពលរដ្ឋមកកែតំរូវឈ្មោះ និងកែទិន្នន័យលើបញ្ជីឈ្មោះបោះឆ្នោតចំនួន ៧.៥៥២នាក់ ។ រកឃើញអ្នកមានឈ្មោះតែគ្មានរូបចំនួន ៤២៤នាក់ ដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឆ្នាំ២០០៦ ។ ប្រជាពលរដ្ឋគ្រប់អាយុបោះឆ្នោត មិនបានទទួលប័ណ្ណព័ត៌មាន និងគ្មានឈ្មោះក្នុងបញ្ជី បានរូតរះមកចុះឈ្មោះចំនួន ៤.៥៧៩ នាក់ ស្រី ២.១៨៣នាក់ ។ ចំនួនឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០០៧ ខាងមុខកើនឡើងដល់ ២១.៣៩៧នាក់ ។ ទិសដៅថ្ងៃមុខ នៅពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ ខាងមុខ គជប នឹងធ្វើការចែកប័ណ្ណព័ត៌មានដល់អ្នកបោះឆ្នោតម្តងទៀត ។ ដូច្នេះយើងសង្ឃឹមថា អ្នកបោះឆ្នោតនិងកាន់តែមានភាពងាយស្រួលក្នុងការរកការិយាល័យបោះឆ្នោត និងរកឈ្មោះរបស់ខ្លួនជាមិនខាន ។ ជាមួយនោះដែរ គជប ក៏បានបន្ថែមមន្ត្រីបោះឆ្នោតក្នុង ១ការិយាល័យ ១នាក់ សំរាប់ជួយរកឈ្មោះជូនអ្នកបោះឆ្នោតផងដែរ ។ ដូច្នេះ លោក សំណូមពរគ្រប់គណបក្សនយោបាយទាំងអស់ អាជ្ញាធរដែនដី ពិសេសប្រធានភូមិ មេត្តាចូលរួមសហការជាមួយគណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់ CEC របស់ លោក ដែលចាប់កំណើតនាចុងខែធ្នូ ឆ្នាំ ២០០៦ ខាងមុខនេះ ។

**៣. អំពីយុទ្ធនាការឃោសនាៈ** ការបោះឆ្នោត ៤ដងកន្លងមក ក្រុងកែបទទួលបានកិត្តិស័ព្ទដ៏ល្អ ដោយពុំមានបញ្ហាអំពីការគំរាមកំហែង ឬការកៀបសង្កត់ ឬការប្រើអំពើហឹង្សាទៅលើបុគ្គលណាមួយឡើយ ។ នេះសបញ្ជាក់ឱ្យឃើញថា គ្រប់គណបក្សនយោបាយ និងប្រជាជនគ្រប់រូបមានការយល់ដឹងកំរិតខ្ពស់ អំពីការដណ្តើមអំណាចតាមរយៈសន្លឹកឆ្នោត ព្រមទាំងសបញ្ជាក់អោយឃើញនូវការអនុវត្តលទ្ធិប្រជាធិប្បតេយ្យនៅក្រុងកែប គឺមានកំរិតខ្ពស់ ។ លទ្ធផលដ៏ល្អនេះ គណៈកម្មាធិការរៀបចំការបោះឆ្នោត បានអនុវត្តកន្លងមកមានដូចជា បានអញ្ជើញគ្រប់សមាសភាពពាក់ព័ន្ធដូចជាកងកំលាំងប្រដាប់អាវុធ អជ្ញាធរមូលដ្ឋាន គ្រប់គណបក្សនយោបាយ អង្គការសង្គមស៊ីវិលមកជួបជុំគ្នាតុមូល ដើម្បីភិភាក្សាប្តូរយោបល់គ្នា យល់ចិត្តថ្លើមគ្នា ព្រមទាំងរកគន្លឹះល្អៗដើម្បីសម្របសម្រួលគ្នាឈានទៅទប់ស្កាត់រាល់អំពើហឹង្សានានាដែលអាចកើតមានឡើងជាយថាហេតុ ។ ក្នុងយុទ្ធនាការឃោសនា លោក បានសំណូមពរគណបក្សនយោបាយធ្វើប្រតិតិនឃោសនារបស់ខ្លួន រួចហើយជួបជុំគ្នាដើម្បីធ្វើសមាហរណកម្មប្រតិទិនឃោសនានោះបញ្ចូលគ្នាតែមួយមិនឱ្យជាន់កម្មវិធីគ្នា ។ បើកន្លែងណាជាន់ពេលវេលា ឬទីកន្លែង យើងត្រូវសម្របសម្រួលគ្នា ។ បន្ទាប់មកគ្រប់សមាសភាពពាក់ព័ន្ធ គ្រប់គណបក្សនយោបាយចុះហត្ថលេខារួមគ្នាទុកជាភស្តុតាង ។ ទីបំផុតយើងអនុវត្តតាមប្រតិទិនតែមួយដែលយើងបានចុះហត្ថលខាជាមួយគ្នានោះ ។

ការអនុវត្តន៏វិធីនេះក្នុងពេលបោះឆ្នោត ៤លើក កន្លងមកនេះ PEC ទទួលបានលទ្ធផលល្អគួរជាទីមោទនៈ ។ បញ្ហានេះ PEC និងខិតខំអនុវត្តបន្តទៀត ដើម្បីបង្កលក្ខណៈឱ្យគ្រប់គណបក្សនយោបាយ គ្រប់សមាសភាពពាក់ព័ន្ធដល់ការបោះឆ្នោត មានឪកាសជួបជុំគ្នាបានកាន់តែញឹកញាប់ និងកាន់តែបង្កបានការយល់ចិត្តយល់ថ្លើមគ្នា បំបាត់បាននូវការមិនយល់ចិត្តគ្នា បញ្ចៀសបាននូវអំពើហឹង្សានានា

ជាមិនខាន ។ ទន្ទឹមនោះដែរ លោក ក៏សូមកោតសរសើរចំពោះកិច្ចសហការដ៏ល្អរបស់អជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ គ្រប់គណបក្សនយោបាយ និងគ្រប់អង្គការក្រៅរដ្ឋាភិបាលដែលបានធ្វើការរួមគ្នាជាមួយអាជ្ញាធរបោះឆ្នោត ក្នុងការទប់ស្កាត់រាល់អំពើហឹង្សានានា ។

**៤. អំពីការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត:** កន្លងមក PEC សង្កេតឃើញមានប្រជាពលរដ្ឋយ៉ាងច្រើនកុះករទៅចូលរួមបោះឆ្នោតនៅគ្រប់ការិយាល័យបោះឆ្នោត ។ នេះសបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋមានការយល់ដឹងខ្ពស់ពីកាតព្វកិច្ចក្នុងការជ្រើសរើសមេដឹកនាំរបស់ខ្លួន ។

ចំពោះការរាប់សន្លឹកឆ្នោត និងបូកសរុបលទ្ធផល មន្ត្រីបោះឆ្នោត PEC ខិតខំអនុវត្តបានយ៉ាងល្អប្រសើរ ។ ទីបំផុតលទ្ធផលនៃការបោះឆ្នោតត្រូវបានគ្រប់ភាគីទទួលយកដោយគ្មានបញ្ហាឡើយ ។ នេះជាជោគជ័យដ៏ធំធេងដែលា PEC ទទួលបានកន្លងមក ។

លោក បានបញ្ជាក់ថា ជោគជ័យដ៏ធំធេងនេះបានមកដោយសារៈ ១. ប្រជាពលរដ្ឋមានការភ្ញាក់រលឹកខ្ពស់ទៅចុះឈ្មោះ និងទៅបោះឆ្នោត ។ ២.គ្រប់គណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ អង្គការសង្គមស៊ីវិល បានសហការគ្នាយ៉ាងចិតស្និតជាមួយអាជ្ញាធរបោះឆ្នោត ។ ដូច្នេះទៅអនាគត់ លោក សំណូមពរគ្រប់សមាសភាពពាក់ព័ន្ធ នឹងការបោះឆ្នោត គ្រប់គណបក្សនយោបាយ អង្គការសង្គមស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ មេត្តាជួយសហការណ៍ជាមួយ PEC បន្តទៀតដើម្បីរៀចចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី២ ឆ្នាំ ២០០៧ និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអណត្តិ ទី៤ ឆ្នាំ ២០០៨ ខាងមុខ អោយកាន់តែទទួលបានលទ្ធផលល្អប្រសើរថែមទៀត ។

លោក **ឪក សេរី សោភក្តិ៍** សូមអរគុណដល់លោកប្រធាន PEC ដែលបានរាយការណ៍យ៉ាងលំអិតទាក់ទង និងការងារបោះឆ្នោតដែលទីក្រុងកែបទទួលបាន ។ លោក សូមកោតសរសើរនិងគោរពគ្រប់ភាគីពាក់ព័ន្ធក្នុងការបោះឆ្នោតទាំងអស់នៅក្រុងកែបនេះដែលមាន លោក ប្រធាន PEC គណបក្សនយោបាយ និងប្រជាពលរដ្ឋដែលបានរួបរួមគ្នាធ្វើឱ្យយន្តការបោះឆ្នោតនៅទីក្រុងកែបកន្លងមកប្រកបដោយជោគជ័យ ដែលក្នុងនាមយើងជាប្រជាពលរដ្ឋខ្មែរមានមោទនភាពណាស់ ដែលយើងអាចធ្វើបានយ៉ាងនេះ ។

លោក **មិន ជីណាត** ក្រុមប្រឹក្សាសង្កាត់ព្រៃធំ គណបក្ស សម រង្ស៊ី បានសួរទៅលោកប្រធាន PEC ថា លក្ខខណ្ឌនៅពេលឃោសនាបោះឆ្នោត តើមានឯកសារអ្វីខ្លះដែលមិនត្រូវប្រើ ហើយមានឯកសារអ្វីខ្លះដែលអាចប្រើបាន និងមិនខុសច្បាប់ ។ ហើយបើគណបក្សណាប្រើខុសតើមានទោសដែរ ឬ ទេ ដល់កំរិតណា?

**លោក ម៉ុក សែន** ឆ្លើយតបនឹងចំណោទខាងលើ លោក បានបញ្ជាក់ថា នៅក្នុងបទបញ្ជានៃនីតិវិធី និងច្បាប់បោះឆ្នោតមានរៀបរាប់លំអិតពីបញ្ហានេះ ។ ដោយសារ លោក មិនបានយកមកជាមួយ លោក មិនហ៊ាននិយាយក្រែងមានខុស ដូច្នេះ លោក បានស្នើឱ្យវាគ្មិនខាងលើពិនិត្យច្បាប់បោះឆ្នោតឡើងវិញ ដើម្បីបានយល់ច្បាស់ពីបញ្ហានេះ ឯបទបញ្ជា និងនីតិវិធីវិញ គឺមាននិយាយស្របនឹងច្បាប់នោះដែរតែលំអិតជាង នៅជំពូកទី៨ ស្តីពីការឃោសនា ទំព័រទី៩០ ដល់ ១០៨ ព្រមទាំងសូមពិនិត្យទំព័រនោះឡើងវិញ ដែលមានបទប្បញ្ញត្តិទូទៅ សំភារៈអប់រំ អ្នកបោះឆ្នោត និងភារកិច្ច កាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយ ។ បើសិនគណបក្សនយោបាយអនុវត្តខុសពីប្រការទាំងនេះ អាចមានទោសទៅតាមធ្ងន់ស្រាល តាំងពីការពិន័យជាប្រាក់ ជាប់ពន្ធនាគារ ។ ការដែលបានលើកឡើងចំណុចនេះមានសារៈសំខាន់ណាស់ ដើម្បីឱ្យអ្នកពាក់ព័ន្ធក្នុងការបោះឆ្នោត គោរពច្បាប់បានទាំងអស់គ្នានោះយើងនឹងអាចជៀសផុតពីជំលោះ ។

លោក **ឱក សេរី សោភក្តិ៍** បានបញ្ជាក់ថា ដោយសារតែមានតម្លាភាពនេះហើយ ដែលធ្វើឱ្យដំណើរការការងារ ខប់សែល ទទួលបានជោគជ័យ ការដែលយើងលើកឡើង គឺមានការទទួលខុសត្រូវ វប្បធម៌នៃការពិភក្សាគ្នា គឺត្រូវតែមានការទទួលខុសត្រូវ នោះហើយទើបយើងក្លាយជាប្រជពលរដ្ឋមានអរិយធម៌ខ្ពស់ ដែលអាចទទួលខុសត្រូវនៅក្នុងការចចេកគ្នា ។ ដូច្នេះជាមោទនៈភាពណាស់ ដែលអស់លោក លោកស្រី ខាងតំណាងក្រុមប្រឹក្សាឃុំបានលើកឡើង ។

**លោក រ៉ុង សាន** តំណាងលេខាបក្ស គណបក្ស សម រង្ស៊ី ប្រចាំក្រុងកែប បានចាប់អារម្មណ៍ទាក់ទងនឹងការធ្វើប័ណ្ណបោះឆ្នោត លោក យល់ថា ប័ណ្ណបោះឆ្នោតដែលអ៊ិនតាក់ធ្វើមានលក្ខណៈងាយស្រួល ដែលប្រជាពលរដ្ឋអាចទៅប្រកបរបររកស៊ីនៅទីណាក៏បាន ដូចជាបានទៅប្រកបរបរនៅកោះកុងធ្វើប័ណ្ណបោះឆ្នោតនៅកោះកុងមិនចាំបាច់ត្រឡប់ទៅមកទេ ដែលធ្វើឱ្យពលរដ្ឋ ចំណាយលុយកាក់ច្រើនលើការងារបោះឆ្នោតនេះ ។ ដូច្នេះ លោក សូមសួរថា ហេតុអ្វីបានជា គជប មិនអនុវត្តបែបនេះទៅ?

**លោក ម៉ុក សែន** បានឆ្លើយតបនឹងវាគ្មិនខាងលើថា កាលសម័យនោះធ្វើប័ណ្ណបោះឆ្នោតហើយ ទៅបោះឆ្នោតនៅកន្លែងណាក៏បាន តែមកដល់ពេលនេះ គឺខុសពីមុន ព្រោះ គជប អនុវត្តតាមច្បាប់ដែលបានកំណត់ដោយរដ្ឋសភា ដូច្នេះ គជប មិនអាចអនុវត្តខុសពីនោះបានទេ ។ តែបើចង់អនុវត្តតាមបែប អ៊ិនតាក់ លោកសំណូមពរថា ថ្នាក់កំពូលគណបក្ស សម រង្ស៊ី គួរតែអាចពិភាក្សានៅរដ្ឋសភាបាន ។

លោក **ឱក សេរី សោភក្តិ៍** បញ្ជាក់បន្ថែមថា ដោយសារមានហេតុផលថា កាលពីជំនាន់អ៊ិនតាក់ មានវត្តមានក្នុងរយៈពេលខ្លីទេ ចំណាយលុយអស់ជាង ២កោដដុល្លារ ហើយមានការប្រតិបត្តិការខាងសន្តិភាព កងកម្លាំង និងអនុវត្តការងារបោះឆ្នោតមួយភាគធំ គឺជិត ១កោដដុល្លារ សំរាប់តែរឿងបោះឆ្នោតមួយមុខ ។ ការអនុវត្តន៏តាមបែបអ៊ិនតាក់ត្រូវមានបំពាក់ប្រព័ន្ធកុំព្យូទ័រថ្លៃធំណាស់ដែលអាចពិនិត្យនៅទីណាក៏បាន ហើយក៏នៅមានខុសច្រើនដែរ ។ ប្រទេសណាដែលទើបចេញពីសង្គ្រាម ដើម្បីកុំឱ្យថ្លៃពេកទើបសុខចិត្តឱ្យពលរដ្ឋចុះឈ្មោះនៅទីណា ត្រូវបោះឆ្នោតនៅទីនោះ ដែលអាចគ្រប់គ្រងបាន បើមិនអញ្ចឹងទេ យើងត្រូវការប្រព័ន្ធគ្រប់គ្រងកុំព្យូទ័រធំ ចំណាយច្រើន ដែលស្រុកយើងមិនទាន់មានលទ្ធភាពទេ ដែលនេះជាហេតុផលមួយក្នុងចំណោមហេតុផលនានា ។ បើ លោក លោកស្រី មិនចាប់អារម្មណ៍អ្វីទេ នៅពេលយើងធ្វើរបាយការណ៍ទៅខេត្តឯទៀត១ នោះគេយល់ថា ដំណើរការរៀបចំការបោះឆ្នោតនៅក្រុងមិនមានបញ្ហាអ្វីស្មុគស្មាញទេ អ្វី១ដំណើរការទៅដោយរលូនល្អជាងខេត្តណា១ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជារឺមួយក៏មានបញ្ហាដែរ តែមិនហ៊ានលើកឡើង ។ ដូច្នេះទាំងពីរបញ្ហានេះមិនដឹងសន្និដ្ឋានថាយ៉ាងណានោះទេ ។

លោក **សឹង ហ៊ត** ចៅសង្កាត់រងទី ១ សង្កាត់កែប មកពី គណបក្ស ប្រជាជន បានចាប់អារម្មណ៏ថា កាលពីមុនយើងផ្អែកទៅលើការចុះឈ្មោះមិនទៀងទាត់ អាយុ ឆ្នាំកំណើតដោយសារកាលពីមុនយើងមិនទាន់មានអត្រានុកូលដ្ឋានត្រឹមត្រូវ តែក្រោយមកនៅពេលមានអត្រានុកូលដ្ឋានជាគោលដោយផ្អែកទៅលើអត្តសញ្ញាណប័ណ្ណ ហើយមួយចំនួនមិនមានអត្តសញ្ញាណប័ណ ។ ដូច្នេះចុះអត្រានុកូលដ្ឋានហើយទើបចុះធ្វើអត្តសញ្ញាណប័ណ្ណ ។ ដូច្នេះឈ្មោះដែលធ្វើអត្រានុកូលដ្ឋានក៏ដោយ ច្បាប់ទំលាប់នៃការចុះឈ្មោះហាក់គ្មានការពិត ហេតុនេះការចុះឈ្មោះបោះឆ្នោត គឺផ្អែកទៅតាមអត្រានុកូលដ្ឋាន ។

លោក **ឱក សេរី សោភក្តិ៍** បានបញ្ជាក់ថាមិនមែនមានតែប្រទេសកម្ពុជាទេដែលពេញចិត្ត និងយន្តការនេះ មានប្រទេសជាច្រើនដែលចង់រៀនសូត្រពីយន្តការនេះ ដូចជាប្រទេសទីម័រខាងកើត អាហ្គានីស្ថាន បានបញ្ជូនអ្នកបច្ចេកទេសរបស់គេ មកជួប លោក ដើម្បីសិក្សាថា តើ ខប់សែល ធ្វើយ៉ាងមេចទើបអាចចចេកគ្នាបាននៅក្នុប្រធានបទដ៏ក្តៅគគុកជុំវិញការបោះឆ្នោតនេះ ។ ទាំងអស់នេះហើយដែលជាមោទនៈភាពរបស់ជាតិយើង ជាពិសេសក្រុងកែបដែលពុំមានបញ្ហាចោទឡើង ។

លោក **ម៉ុក សែន** បានថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ និងវិទ្យាស្ថាន វបសអ ដែលបានរៀបចំកម្មវិធីជួបជុំគ្នានៅព្រឹកនេះ និងដើម្បីរកគន្លឹះដោះស្រាយបញ្ហានានាទាក់ទង នឹងការបោះឆ្នោត ។ នៅក្នុងក្រុបកែបនេះ មិនដែលមានបញ្ហាអ្វីដែលលំបាកដោះស្រាយជាមួយគ្នាទេ ដោយយើងអនុវត្តវប្បធម៌ពិភាក្សាគ្នានេះជាច្រើនដងរួចមកហើយតាមការណែនាំរបស់ គជប ។ យើងតែងជួបគ្នាជាញឹកញាប់ក្នុងមួយអាទិត្យម្តង ដោយលើកបញ្ហាចំៗនៅចំពោះមុខគ្នា នៅទីបំផុតយើងអាចសំរបសំរួលគ្នាបាន ដែលនេះជាការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សមានកំរិតខ្ពស់ ។ ដូច្នេះសូមកោតសរសើរដល់គ្រប់ គណបក្ស នយោបាយ ដែលមានការយល់ចិត្តគ្នាទៅវិញទៅមក ហើយសូមឱ្យអស់លោក លោកស្រី អនុវត្តបែបនេះតទៀតសំរាប់ការបោះឆ្នោត ឆ្នាំ២០០៧-២០០៨ នៅពេលខាងមុខនេះ ។

លោក **ឳក សេរី សោភក្តិ** បានសំណូមពរថា ដោយក្រុងកែបពុំសូវមានបញ្ហាចោទឡើងច្រើន ដូច្នេះសូមឱ្យ ខប់សែលប្រ៉មក្រុងកែបលើកក្រោយបញ្ចូលជាមួយ ខេត្តកំពត តែម្តង គឺធ្វើរួមទាំងពីរចូលគ្នាតែមួយ ដើម្បីឱ្យលើកបញ្ហាសរុបតែម្តង ។ មួយវិញទៀត អាចជាឱកាសឱ្យលោក ប្រធាន PEC ខេត្តកំពត និង លោក ប្រធាន PEC ក្រុងកែប មានឧកាសបានចចែកពិភាក្សាជម្រាបជូនអង្គប្រជុំនៅពេលនោះ ដែលយើងហៅថាអង្គប្រជុំរួម ដើម្បីបានស្តាប់ពីគ្នាទៅវិញទៅមក ។

លោក **Larry Stange** ជាថ្មីម្តងទៀតលោកសូមសម្តែងការរីករាយណាស់ដែលបានមកចូលរួមតាំងពីចាប់ផ្តើមរហូតដល់ចប់ ។ លោក សូមសរសើរដោយស្មោះស្ម័គចំពោះគុណភាពនៃការពិភាក្សានៅព្រឹកនេះ ដែលជាការបង្ហាញពីការចាប់ផ្តើម មួយដែលយើងកំពុងតែធ្វើឱ្យមានលិទ្ធិប្រជាធិបតេយ្យប្រកបដោយចាស់ចិត្តចាស់គំនិតនេះ ។ លោកសន្យាថា និងរាយការណ៍ជូនទៅកិច្ចប្រជុំថ្នាក់ជាតិពីលទ្ធផលជាវិជ្ជមាន និងបទពិសោធន៍នៅក្រុងកែបនេះជូនទៅអ្នកចូលរួមនានានៅថ្នាក់ជាតិ ជាពិសេសនៅកិច្ចប្រជុំខប់សែលឡឹម ។ គោលបំណងសំខាន់ នៃគ្រប់កិច្ចប្រជុំ ខប់សែលប្រ៉ម ថ្នាក់ខេត្តក្រុងនិមួយៗ គឺធ្វើយ៉ាងណាឱ្យការផ្តល់ព័ត៌មាន ការទទួលព័ត៌មានជុំវិញការបោះឆ្នោត ឱ្យបានសុក្រឹត្យនិងត្រឹមត្រូវជាទីបំផុត ដែលជាកត្តាសំខាន់ក្នុងការជំរុញឱ្យមានតម្លាភាព ក្នុងដំណើរការរៀបចំការបោះឆ្នោត ក៏ដូចជាការរៀបចំការបោះឆ្នោតមួយដ៏ត្រឹមត្រូវ និងយុត្តិធម៌ ដែលអាចទទួលយកបាន ។ ជាចុងក្រោយនេះ លោក សូមចែករំលែកនូវបទពិសោធន៍មួយដែលក្នុងនាម លោក ជាជនបរទេស ជនជាតិអូស្ត្រាលីដែលទើបតែមកធ្វើការនៅស្រុកខ្មែរប្រហែលជាង៣ឆ្នាំនេះ លោកបានបញ្ជាក់ថា ប្រទេសអូស្ត្រាលីគឺជាប្រទេសមួយដែលមានអាយុកាលប្រហែលជា១០០ ឆ្នាំទេ ប៉ុន្តែពោរពេញទៅដោយការអនុវត្តន៍លិទ្ធិប្រជាធិបតេយ្យដ៏រឹងមាំ និងចាស់ចិត្តចាស់គំនិត ហើយទទួលបានការកោតសរសើរពីមជ្ឈដ្ឋានទូទាំងពិភពលោកផងដែរ ។ តាមប្រវត្តិសាស្ត្រប្រទេសអូស្ត្រាលី គឺយើងបានរៀនសូត្រជាច្រើនដើម្បីធ្វើយ៉ាងណាធានាឱ្យបាន ប្រកបដោយលិទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។

មួយទៀតដំណើរការនៅក្នុងការដែលធ្វើឱ្យរដ្ឋធម្មនុញ្ញប្រកបដោយលិទ្ធិប្រជាធិបតេយ្យពិតប្រាកដនៅប្រទេសអូស្ត្រាលី ក្នុងពេលសព្វថ្ងៃនេះ គឺទាមទារពេលវេលាជាច្រើនទស្សវត្ស ដើម្បីក៏សាងពីមួយដំណាក់កាលទៅមួយដំណាក់កាលធ្វើយ៉ាងណាដើម្បី ឱ្យធម្មនុញ្ញនៃលិទ្ធិប្រជាធិបតេយ្យនេះមានពិតប្រាកដនៅក្នុងប្រទេស ។ កាលដែលក៏សាងបាននូវធម្មនុញ្ញប្រកបដោយលិទ្ធិប្រជាធិបតេយ្យបាន ដោយសារមានការចូលរួមយ៉ាងខ្លាំងជាពិសេសការឯកភាពគ្នានៅក្នុងសង្គម ទាំងផ្នែកសហគមន៍ ភាគីពាក់ព័ន្ធនានា គណបក្សនយោបាយ ដើម្បីធ្វើយ៉ាងណាជួយជម្រុញឱ្យការឯកភាពនេះឆ្ពោះទៅរកលិទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ មេរៀនមួយទៀតដែល លោក សូមចែករំលែកផងដែរនោះ គឺនៅលើពិភពលោកយើងនេះ លិទ្ធិប្រជាធិបតេយ្យពុំមែនមានទំរង់ ឬបែបបទតែមួយ

ទេ គឺអាស្រ័យទៅលើប្រទេសនីមួយៗដែលគាត់អនុម័ត ឬសំរេចយកទៅតាមប្រធានបទ ឬបរិបទរបស់ប្រទេសនោះ ដូចជាប្រទេសអូស្ត្រាលីមានបែបទមួយនៃលទ្ធិប្រជាធិប្បតេយ្យ ក៏ដូចជាប្រទេសកម្ពុជាយើងដែរ មានទម្រង់លទ្ធិប្រជាធិប្បតេយ្យផ្សេងៗគ្នា ។

ពេលនេះលោក សូមលើកឡើងម្តងទៀតសូមកោតសរសើរយ៉ាងស្មោះស្ម័គ្រ ចំពោះការចូលរួមរបស់លោកស្រី អស់លោកក្នុងការលើកឡើងពិភាក្សាគ្នា ដើម្បីជាចំណុចមួយដែលយើងអាចបង្ហាញថា នេះជាដំណើរការមួយដែលយើងកំពុងតែវិវត្តនទៅរកការកសាងលិទ្ធិប្រជាធិបតេយ្យមួយដ៏ចាស់ចិត្តចាស់គំនិត ដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតប្រកបទៅបានល្អ ។

ជាថ្មីម្តងទៀត លោក សូមអរគុណដល់ឯកឧត្តម ហាស់ សារ៉េត អភិបាលក្រុងកែប និងលោក ប្រធាន លេខាធិការដ្ឋានរៀបចំការបោះឆ្នោតក្រុងកែប ដែលបានគាំទ្រចំពោះយន្តការនេះ និងអនុញ្ញាតិឱ្យ វិទ្យាស្ថាន CDRI បានរៀបចំការប្រជុំព្រឹកនេះ ។ លោកក៏សូមថ្លែងអំណរគុណផងដែរដល់លោក ឱក សេរី សោភក្តិ៍ ដែលបានសម្របសម្រួលយន្តការ ខប់សែល នេះ ប្រកបដោយភាពប៉ុនប្រសព្វ និងសូមអរគុណដល់ក្រុមការងារ ខប់សែល ព្រមទាំងអង្គការសហប្រជាជាតិ UNDP ដែល បានគាំទ្រកម្មវិធីនេះតាំពីដើមរហូតមកដល់ពេលនេះ ។ ជាចុងក្រោយលោក សូមថ្លែងអំណរគុណចំពោះការចូលរួមនៅក្នុងការពិភាក្សារបស់អស់លោក លោកស្រីនៅក្នុងព្រឹកនេះ ។

**លោក ឱក សេរី សោភក្តិ៍** ក្នុងយន្តការ ខប់សែល នេះ ក្រុងកែប គឺជា ឧទាហរណ៍ មួយដ៏ល្អដែលក្រុងនិងខេត្តឯទៀតៗគួរយកតម្រាប់តាម នេះជាមោទនៈភាពរបស់ជាតិទាំមូលដែលក្រុងកែបអាចធ្វើដូច្នេះបាន ។ លោក និងយកគំរូដ៏ល្អនេះទៅរាយការណ៍នៅថ្នាក់ជាតិបន្តទៀត ។